ព្រះរាជាណាចក្រកម្ពុជា

ស្ថានឯកអគ្គរាជទូតកម្ពុជា

ប្រចាំសាធារណរដ្ឋកូរ៉េ

លេខ: ៣២១.០៩.សកស

ជាតិ សាសនា ព្រះមហាក្សត្រ

សេអ៊ូល, ថ្ងៃទី ០៨ ខែកក្កដា ឆ្នាំ ២០០៩

**សូមគោរពជូន**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

**និងជា រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ:** របាយការណ៍លទ្ធផល សិក្ខាសាលាស្តីពី ការលើកកំពស់ប្រសិទ្ធភាពជំនួយ

ខ្ញុំបាទមានកិត្តិយសសូមជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា លោកទីប្រឹក្សាពាណិជ្ជកម្ម បានចូលរួមសិក្ខាសាលាការលើកកំពស់ប្រសិទ្ធភាពជំនួយ Enhancing Aid Efffectiveness 2009 សិក្ខាសាលាប្រព្រឹត្តទៅកាលពីថ្ងៃទី ២៩ មិថុនា ២០០៩ រៀបចំដោយ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសកូរ៉េ Korea International Cooperation Agency (KOICA) ដែលមានការចូលរួមយ៉ាងច្រើនកុះករ ពីសំណាក់អង្គភាពពាក់ព័ន្ធការផ្តល់ជំនួយ តំណាងស្ថានទូតនៃប្រទេសកំពុងអភិវឌ្ឍ និងតំណាងប្រទេសផ្តល់ជំនួយ ។ សិក្ខាសាលាបានទទួលលទ្ធផលដូចតទៅ:

- លើកកំពស់ការអនុវត្តការងារ ដើម្បីសំរេចគោលដៅក្នុងការប្រគល់ជំនួយទៅតាមផែនការ និងប្រកបដោយប្រសិទ្ធភាព ដែលជាមុខសញ្ញាសំខាន់របស់ប្រទេសផ្តល់ជំនួយ គឺ ការកាត់បន្ថយភាពក្រីក្រ បង្កើនសុខមាលភាពសង្គម ការអភិវឌ្ឍធនធានមនុស្ស លើកកំពស់កំរិតជីវភាពរស់នៅរបស់ប្រជាជន ។ល។
- ពិគ្រោះនិងតាមដាន ចំពោះរាល់បណ្តាមុខសញ្ញាជំនួយ ដើម្បីតម្រង់ឆ្ពោះចំគោលដៅអភិវឌ្ឍ និងជាតម្រូវការចាំបាច់របស់ប្រទេសជាដៃគូ ។
- ទិសដៅកែលំអ អោយការចំណាយរបស់ប្រទេសផ្តល់ជំនួយ ទាំងជំនួយឥតសំណង ជំនួយជាកម្ចីសម្បទាន ជំនួយសហប្រតិបត្តិការ បានទទួលនូវលទ្ធផលផ្លែផ្កា រយៈពេលខ្លី-មធ្យម-វែង ។
- កាត់បន្ថយចរន្តនិងបែបបទ ដែលបណ្តាលអោយមានការអូសបន្លាយពេលវេលា ជាមូលហេតុនាំអោយមានការលំបាក និងរអាក់រអួល ក្នុងការអនុវត្តនិងការបំពេញបែបបទទួលជំនួយ ។
- កូរ៉េបានលើកឡើងនិងជំរាបអំពីបទពិសោធន៍របស់ខ្លួន ក្នុងនាមជាប្រទេសទទួលជំនួយ កាលពីអតីតកាល និងបទពិសោធន៍ព្រមទាំងជំហររបស់ខ្លួន ក្នុងការផ្តល់ជំនួយដល់បណ្តាប្រទេសជាដៃគូ ។

Royal Embassy of Cambodia
653-110 Hannam-dong
Yongsan-gu, Seoul 140-887
Republic of korea

Tel 82 2 3785 1041
Fax : 82 2 3785 1040
E-mail : camboemb@korea.com

- ភាគីជាតំណាងប្រទេសផ្តល់ជំនួយ នឹងពិនិត្យជាទៀងរាល់ពីរឆ្នាំម្តង ព្រមទាំងជំរុញអោយមានការចូលរួមកាន់តែច្រើនកុះករ ពីសំណាក់អាជ្ញាធរ ស្ថាប័នជំនាញបច្ចេកទេសអភិវឌ្ឍ ទៅតាមវិស័យជាក់លាក់នីមួយៗ ។
- ប្រទេសន័រវេស៍ ត្រូវបានលើកឡើងនិងជំរាបជូនថា ជាប្រទេសមានគំរូជោគជ័យ ក្នុងការគ្រប់គ្រងនិងបែងចែកភោគផលធនធានធម្មជាតិ ប្រេងឥន្ធនៈ និងអភិវឌ្ឍសេដ្ឋកិច្ចបានរីកចំរើនឆាប់រហ័ស ។
- រីឯប្រទេសកូរ៉េ ជាគំរូសិក្សាដែលឈានឋានៈពីប្រទេសទទួលជំនួយ មកជាប្រទេសផ្តល់ជំនួយ ក្នុងរយៈពេលដ៏ខ្លី និងបានដំណើរការកសាងសេដ្ឋកិច្ច រីកចំរើនគួរអោយចាប់អារម្មណ៍ ។
- ក្នុងពេលជាមួយគ្នានោះដែរ កូរ៉េក៏បានលើកឡើងអំពីចំណុចខ្វះខាតរបស់ខ្លួន មួយចំនួនផងដែរ ដែលជាហេតុធ្វើអោយមានការយឺតយ៉ាវ ក្នុងកិច្ចដំណើរការនៃផែនការផ្តល់ជំនួយ តែចំណុចចន្លោះប្រហោងនោះនឹងត្រូវយកមកធ្វើការកែលំអអោយបានប្រសើរឡើង ។

<u>**កំណត់ចំណាំ:**</u> ក្នុងកិច្ចពិភាក្សាជាមួយ លោកស្រី Sooyoung Park ប្រធានការិយាល័យវាយតម្លៃ នៃទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ ស្ថានទូតកម្ពុជា បានស្នើអោយមន្ត្រី KOICA ជួយជំរុញគម្រោងសាងសង់មន្ទីរពេទ្យនៅស្រុកបាធាយ ខេត្តកំពង់ចាម ដែលគ្រោងដាក់ឈ្មោះជា **មន្ទីរពេទ្យមិត្តភាព កម្ពុជា-កូរ៉េ** ។ ភាគីកូរ៉េ បានជូនយោបល់ថា គំរោងសាងសង់មន្ទីពេទ្យនេះ កំពុងស្ថិតនៅក្នុងកិច្ចដំណើរការអនុវត្ត ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបជារបាយការណ៍ ដ៏ខ្ពង់ខ្ពស់ ។

សូមឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំបាទ ។

**ឯកអគ្គរាជទូត**

**លឹម សំកុល**

<u>**ចម្លងជូន :**</u>

**-ក្រសួងពាណិជ្ជកម្ម**

" ដើម្បីជូនជ្រាប "

-ឯកសារ-កាលប្បវត្តិ